ក្រុមប្រឹក្សារដ្ឋ
លេខ ០៤ ក្រ.ច

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ-ច្បាប់

## ស្តីពី

## ការចាត់តាំងតុលាការយោធា

## ក្រុមប្រឹក្សារដ្ឋ

បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

ដើម្បីការពារសន្តិសុខ ការពារប្រទេស ការពារកម្លាំងប្រយុទ្ធរបស់កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា ពង្រឹងវិន័យរបស់កងទ័ព និងការពារនីត្យានុកូលភាព ។

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារប្រទេស និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រមផង ។

**<u>សម្រេច</u>**

**មាត្រា ១** ត្រូវបានបង្កើតុលាការយោធា ដើម្បីជំនុំជម្រះ ។

យោធាដែលប្រព្រឹត្តបទល្មើស ដូចមានកំណត់ក្នុងក្រឹត្យ-ច្បាប់លេខ០២ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ ឬ បទល្មើសដែលមានលក្ខណៈយោធា ឬ បទល្មើសផ្សេងៗទៀត ដែលមានចែងក្នុងច្បាប់ជាធរមាន ។

ជនទាំងឡាយដែលធ្វើការនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារប្រទេស ហើយប្រព្រឹត្តបទល្មើសដែលមានការទាក់ទងដល់កងទ័ព ។

ជនណាដែលប្រព្រឹត្តបទល្មើស បណ្តាលអោយប៉ះពាល់ដល់ផលប្រយោជន៍របស់កងទ័ព ។

បើនៅក្នុងរឿងណាមួយមានយោធា និងជនស៊ីវិលប្រព្រឹត្តបទល្មើសជាមួយគ្នាតាមគោលការណ៍បទល្មើសនេះត្រូវចូលក្នុងសមត្ថកិច្ចរបស់តុលាការយោធា ។ ប៉ុន្តែយោងទៅតាមលក្ខណៈនៃបទល្មើសនីមួយៗ តុលាការយោធាអាចសម្រេចបំបែករឿងផ្សេងពីគ្នា ហើយជំនុំជម្រះតែយោធា ចំណែកជនស៊ីវិលត្រូវបញ្ជូនទៅតុលាការប្រជាជនជំនុំជម្រះ ។ ក្នុងករណីពិសេសតុលាការយោធា អាចបញ្ជូនសំណុំរឿងទាំងមូលទៅតុលាការប្រជាជនជំនុំជម្រះ ។

**មាត្រា ២** កុលាការយោធាមាន ប្រធាន អនុប្រធាន និងចៅក្រមម្នាក់ទៀតជាសមាជិក ។

នៅពេលជំនុំជម្រះក្រុមប្រឹក្សាជំនុំជម្រះមានចៅក្រមម្នាក់ជាប្រធាន និងយោធាពីរនាក់ជាទីប្រឹក្សា ។

ទីប្រឹក្សាយោធា មានសិទ្ធិស្មើនឹងចៅក្រម ។

ក្រុមប្រឹក្សាជំនុំជម្រះធ្វើការជាសមូហភាព និងសម្រេចតាមមតិភាគច្រើន ។

លេខាធិការនៃសវនាការត្រូវកត់ត្រា និងធ្វើកំណត់ហេតុនៃការជំនុំជម្រះព្រមទាំងបំពេញភារកិច្ចផ្សេងទៀតតាមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៣** តំណាងអយ្យការមាន រដ្ឋអាជ្ញាយោធា និងមានភារកិច្ចសម្រេចពីការលើកលែងចោទប្រកាន់ ឬ ពីការចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ការពារការចោទប្រកាន់នៅមុខតុលាការយោធា ហើយរ៉ាប់រងការអនុវត្តន៍សាលក្រម អោយបានសមស្របតាមច្បាប់ ។

**មាត្រា ៤** បើមានបទល្មើសមួយកើតឡើងអាជ្ញាធរយោធា ចាប់ពីថ្នាក់កងអនុសេនាធំ និងកងវរសេនាតូចឡើងទេ ។ ព្រមទាំងកម្មាភិបាលយោធាទទួលបន្ទុកស៊ើបអង្កេតរឿងត្រូវចាត់ជាបន្ទាន់នូវវិធានកចាំបាច់ និងស្របច្បាប់ដើម្បីចាប់ជនប្រព្រឹត្តបទល្មើសរក្សាទុកដាននិងសញ្ញា ជួយព្យាបាលជាបន្ទាន់ដល់ជនរងគ្រោះមានរបួសការពារ

ទ្រព្យសម្បត្តិសាធារណៈ ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន ប្រមូលឯកសារនិងភស្តុតាង ដែលទាក់ទងនឹងបទល្មើស ធ្វើការអង្កេតស៊ើបសួរ ហើយបញ្ជូនសំណុំរឿងមករដ្ឋអាជ្ញាយោធា ។

**មាត្រា ៥** សេចក្តីសម្រេចចោទប្រកាន់ និងសេចក្តីសម្រេចដាក់រឿងជំនុំជម្រះត្រូវអោយដំណឹងដល់ជនជាប់ចោទ បីថ្ងៃយ៉ាងយូរមុនថ្ងៃជំនុំជម្រះ ។

**មាត្រា ៦** សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទត្រូវបានធានា ។

ជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹងអ្នកដទៃណាមួយឲ្យជួយការពារ ។ ក្នុងករណីចាំបាច់ តុលាការយោធាអាចចាត់តាំងមេធាវីម្នាក់អោយជួយការពារដល់ជនជាប់ចោទ ។

**មាត្រា ៧** តុលាការយោធា ជំនុំជម្រះជាលើកទី ១ និងជាលើកចុងក្រោយបង្អស់ ។ សាលក្រមនិងសេចក្តីសម្រេចទាំងឡាយ របស់តុលាការយោធាមានលក្ខណៈជាស្ថាពរគូរក្តី គ្មានសិទ្ធិប្តឹងឧទ្ធរណ៍ឡើយ ប៉ុន្តែសាលក្រមកាត់ទោសប្រហារជីវិត ត្រូវដាក់ជូនក្រុមប្រឹក្សារដ្ឋពិនិត្យជាមុនសិនមុននឹងយកទៅអនុវត្ត ។ ជនដែលត្រូវបានផ្តន្ទាទោសប្រហារជីវិត អាចសុំអនុគ្រោះទោសពីក្រុមប្រឹក្សារដ្ឋក្នុងរយៈ៧ថ្ងៃគិតតាំងពីថ្ងៃដែលប្រកាសសាលក្រម ។

**មាត្រា ៨** ប្រធានតុលាការយោធា អនុប្រធានតុលាការយោធា ចៅក្រម តំណាងអយ្យការយោធា ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងការពារប្រទេស ។ ទីប្រឹក្សាយោធា ត្រូវបានជ្រើសរើសដោយអង្គការទទួលបន្ទុកកិច្ចការនយោបាយនៃកងទ័ព ។

**មាត្រា ៩** រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តក្រឹត្យ-ច្បាប់ តាមភារកិច្ចរៀងៗ ខ្លួន ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១

ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហេង សំរិន**

បានទទួលទអនុវត្ត

ជ.ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ចាន់ ស៊ី**